**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙✵៙

កិច្ចព្រមព្រៀង

ស្តីពីការព្យួរកិច្ចសន្យាការងាររវាងតំណាងនិយោជិត និងក្រុមហ៊ុន អឹបៅអេស៊ា កាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២១ វេលាម៉ោង ៨ និង ៣០នាទីព្រឹក មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន អឹបៅអេស៊ា មានទីតាំងនៅភូមិត្រពាំងសេះ សង្កាត់គោកចក ខេត្តសៀមរាប។

សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន:

| | | |
|---|---|---|
| ក. ភាគីនិយោជក (តំណាងឲ្យក្រុមហ៊ុន) | តួនាទី | លេខទូរស័ព្ទទំនាក់ទំនង |
| លោក ជា សេងហាក់ | ប្រធានផ្នែកធនធានមនុស្ស | 010 777 441 |
| | | |
| ខ. ភាគីនិយោជិក(តំណាងឲ្យបុគ្គលិក) | តួនាទី | លេខទូរស័ព្ទទំនាក់ទំនង |
| កញ្ញា ឡុង ឆេងលាង | បុគ្គលិកផ្នែកលក់ | 010 604 247 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនិងការព្យួរឲ្យបានសមស្របតាមសេចក្តីណែនាំលេខៈ ០៤៥/២០កប/ស.ណ.ន.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារទាំងអស់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២១ ដោយទទួលប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលម្នាក់ៗចំនួន ៤០ដុល្លាអាមេរិកក្នុងរយៈពេលព្យួរកិច្ចសន្យាការងារនេះ។ សម្រាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់បុគ្គលិកក្នុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ ១៩ បាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ៩ និង ០០នាទីព្រឹក នាថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២១ ដោយមានការចុះហត្ថលេខាព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបាននៅចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោមៈ

| | |
|---|---|
| **ភាគីនិយោជកតំណាងឲ្យនិយោជក** | **ភាគីតំណាងឲ្យនិយោជិក** |
| **ហត្ថលេខ/ស្នាមមេដៃ** | **ហត្ថលេខា/ស្នាមមេដៃ** |
| ABOUT ASIA Co., Ltd. | |
| ជា សេងហាក់ | ឡុង ឆេងលាង |